**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

នាឱកាសដ៏ឧត្តុង្គឧត្តម ប្រពៃថ្លៃថ្លាដែល **សម្តេចតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទទួលបានពានរង្វាន់ **ប្រធានគណៈកម្មាធិការអូឡាំពិកអន្តរជាតិ** « IOC President s Trophy » ពី**ប្រធានគណៈកម្មាធិការអូឡាំពិកអន្តរជាតិ** តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមសម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយ ឥតឧបមា និងអបអរសាទរយ៉ាងក្លៀវក្លាបំផុត ចំពោះ **សម្តេចតេជោ** ដែលទទួលបាននូវពានដ៏វិសេសវិសាលអស្ចារ្យ ជាពានរង្វាន់ដ៏ខ្ពស់បំផុតរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ។

សក្ខីភាពទាំងនេះ សរបញ្ជាក់អោយឃើញថា **សម្តេចតេជោ** គឺជាថ្នាក់ដឹកនាំគំរូ និងដ៏កម្រមួយដែលបានបូជាអស់កម្លាំងកាយចិត្ត ស្មារតី សំភារៈ ថវិកា ពេលវេលាយ៉ាងច្រើនដើម្បីបុព្វហេតុជាតិ និងលើកកម្ពស់វិស័យកីឡាចាប់ពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន ដោយបានចាប់ផ្តើមឡើងវិញពីគ្រូបង្វឹក និងកីឡាករល្បីៗ ដែលនៅសេសសល់តិចតួច ពីការកាប់សម្លាប់របស់ពួកប៉ុលពត។ កត្តាទាំងនេះប្រសិនបើប្រទេសជាតិគ្មានសុខសន្តិភាព ស្ថិរភាពនយោបាយ ថ្នាក់ដឹកនាំគ្មានឆន្ទៈមោះមុត វិស័យកីឡានៅកម្ពុជាក៏មិនអាចរីកចម្រើនដូចសព្វថ្ងៃបានឡើយ។ នេះគឺជាមហាកិត្តិយសដ៏ឧត្តុង្គឧត្តម សម្រាប់ **សម្តេច** និងក្រុមគ្រួសាររបស់ **សម្តេច** ក៏ដូចជាសម្រាប់ប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូល ជាការឆ្លើយតបយ៉ាងស័ក្តិសមបំផុតចំពោះស្នាដៃរបស់ **សម្តេច** ក្រោមកម្មវិធីនយោបាយដ៏ត្រឹមត្រូវ គួបផ្សំនឹងភាពប៉ិនប្រសព្វ ប្រកបដោយភាពឈ្លាសវៃ និងស្វាមីភក្តិចំពោះជាតិមាតុភូមិ នាំមកនូវការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវអំណរសាទរនិងគោរពជូនពរ ចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រីទាំងអស់ សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ បញ្ញាញាណភ្លឺថ្លា សូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៧ខែមករាឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**